**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះតុលាការកំពូល |
| **ថ្ងៃដាក់** | : | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 31-Mar-2020, 13:35
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់ ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រកំណត់ ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោកស្រី Brenda J. HOLLIS

**អ្នកទទួលឯកសារ:**

**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra. N. JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
លោក ពេជ អង្គ
លោកស្រី Megan HIRST

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្តី ខៀវ សំផន**
លោក គង់ សំអុន
លោកស្រី Anta GUISSÉ

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់ ខៀវ សំផន[1] ទៅនឹងសំណើ[2] របស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រកំណត់ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខដ៏វែង[3] របស់គាត់ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២[4]។ ការប្រឆាំងរបស់ ខៀវ សំផន ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា គួរត្រូវបានបដិសេធដោយសារគាត់យល់ច្រឡំទៅលើខ្លឹមសារឧបសម្ព័ន្ធ ក ដែលភ្ជាប់ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់គាត់ដែលមានចំណងជើងថា "សេចក្តីសង្ខេបនៃទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន"[5]។ ជាការបន្ថែម ចម្លើយតបរបស់ ខៀវ សំផន គួរត្រូវបានបដិសេធដោយសារចម្លើយតបនេះ (i) ធ្វើមិនដឹងមិនឮចំពោះការពិតថា សារណាពីមុនរបស់គាត់តាមរយៈការបង្រួមដោយសេចក្តីយោងក្នុងសារណានៃបណ្តឹងសាទុក្ខរបស់គាត់នោះ តម្រូវឱ្យសហព្រះរាជអាជ្ញាធ្វើការឆ្លើយតបជាក់លាក់សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធី *បច្ចុប្បន្ន* ដែលស្ថិតនៅក្នុងដំណាក់កាលប្តឹងសាទុក្ខ និង *នៅក្រោយពេល* ដែលសាលក្រមបានចេញ និង (ii) សន្មតទាំងខុសថា ការបន្ថែមចំនួនទំព័រកំណត់ទៅនឹងសារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញា នឹងធ្វើឱ្យមានការពន្យារពេលដល់ដំណើរការបណ្តឹងសាទុក្ខ។ អាស្រ័យដោយមូលហេតុទាំងនេះ ដូចបានរៀបរាប់យ៉ាងលម្អិតខាងក្រោម សំណើរបស់ ខៀវ សំផន សុំឱ្យបដិសេធលើពាក្យសុំរបស់សហព្រះរាជអាជ្ញា គឺគ្មានអង្គសេចក្តីទេ។

## II. សេចក្តីសន្និដ្ឋាន

### ក. ឧបសម្ព័ន្ធ ក របស់ ខៀវ សំផន មិនរួមចំណែកជាសារវន្តដល់សារណាបណ្តឹងសាទុក្ខរបស់គាត់ទេ ដែលគួរត្រូវបានបដិសេធដោយសារច្រើនហួសចំនួនទំព័រកំណត់ ឬប្រសិនបើវារួមចំណែកជាសារវន្តដល់

---

[1] ឯកសារ **F55/1** ចម្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន ទៅនឹងសំណើសុំបន្ថែមចំនួនទំព័ររបស់សហព្រះរាជាអាជ្ញា, ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ("ចម្លើយតបរបស់ ខៀវ សំផន")។

[2] **F55** សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រកំណត់សម្រាប់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ("សំណើរបស់សហព្រះរាជអាជ្ញា")។

[3] ឯកសារ **F54** Mémoire d'Appel de Khieu Samphân (002/02), ចុះថ្ងៃទី២៧ ខែកម្ភៈ ឆ្នាំ២០២០ ("សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី")។ ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក – Résumé des Motifs d'Appel de Khieu Samphân (002/02), ចុះថ្ងៃទី២៧ ខែកម្ភៈ ឆ្នាំ២០២០ ("ឧបសម្ព័ន្ធ ក ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី")។

[4] ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

[5] ឯកសារ **F54.1.1** ឧបសម្ព័ន្ធ ក ទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី (ការបកប្រែក្រៅផ្លូវការ)។

# សារណាបណ្តឹងសាទុក្ខរបស់គាត់មែន នោះចម្លើយតបរបស់សហព្រះរាជអាជ្ញា ក៏សមទទួលបានការអនុញ្ញាតឱ្យបន្ថែមចំនួនទំព័រកំណត់ដែរ

2. ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") ទទួលយកអំណះអំណាងថា ខៀវ សំផន មានភាពជឿនលឿនទៅមុខពិតប្រាកដមែន មានន័យថា ឧបសម្ព័ន្ធ ក មិនបានបន្ថែមអ្វីមួយជាសំខាន់ដល់សារណាបណ្តឹងសាទុក្ខរបស់គាត់ទេ[6] នោះអង្គជំនុំជម្រះនេះគួរទាត់ចោលឧបសម្ព័ន្ធ ក នេះ ដោយសារតែវាលើសចំនួនទំព័រដែលបានកំណត់ត្រឹម ៧៦ ទំព័រ[7]។

3. តាមជម្រើសផ្សេង បើសិនជាអង្គជំនុំជម្រះពិចារណាថា ឧបសម្ព័ន្ធ ក *ពិតជា* រួមចំណែកជាសារវ័ន្តដល់បណ្តឹងសាទុក្ខរបស់ ខៀវ សំផន មែន នោះសហព្រះរាជអាជ្ញាត្រូវតែទទួលបានការបន្ថែមចំនួនទំព័រតាមសំណើសុំរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងឧបសម្ព័ន្ធនេះ។ ឧបសម្ព័ន្ធ ក ផ្តល់គោលការណ៍ណែនាំជាក់ស្តែងអំពីខ្លឹមសារនៃទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និងបង្ហាញច្បាស់ពីអ្វីដែលគាត់ចោទប្រកាន់នៅក្នុងបណ្តឹងសាទុក្ខរបស់គាត់ ប្រឆាំងនឹងសាលក្រមសាលាដំបូង។ នៅក្នុងឯកសារនេះ គាត់បំភ្លឺអំពីខ្លឹមសារនៃបណ្តឹងសាទុក្ខរបស់គាត់ រួមទាំងការធ្វេសប្រហែស ឬភាពខុសគ្នាដែលមាននៅក្នុងនោះ។ ជាការបន្ថែម ឯកសារនេះបង្គ្រប់ទៅលើអំណះអំណាងដែលមាននៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់ តាមរយៈការកំណត់អត្តសញ្ញាណ ជាឧទាហរណ៍ ថាតើកំហុសរបស់អង្គជំនុំជម្រះសាលាដំបូងដូចបានចោទប្រកាន់ បានបំពេញតាមបទដ្ឋាននៃការពិនិត្យឡើងវិញលើបណ្តឹងសាទុក្ខដោយរបៀបណាទាក់ទងនឹងផលវិបាក និងផលប៉ះពាល់នៃកំហុសទាំងនេះ។ អាស្រ័យហេតុនេះ ខៀវ សំផន បានកំណត់នៅក្នុងឧបសម្ព័ន្ធ ក ដែលមានចំនួន ៧៦ ទំព័រ នូវសេចក្តីសង្ខេបនៃអំណះអំណាងដែលគាត់ចង់ធ្វើនៅក្នុងសារណានៃបណ្តឹងសាទុក្ខចំនួន ៧៥០ ទំព័រ របស់គាត់។

4. ឧបសម្ព័ន្ធ ក ជាធរមាន ផ្តល់ផែនទីបង្ហាញផ្លូវអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជាពិសេសបញ្ជាក់ និងជួយដល់ភាគីក្នុងការឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពទៅនឹងបណ្តឹងសាទុក្ខ ហើយអង្គជំនុំជម្រះដោះស្រាយវាប្រកបដោយប្រសិទ្ធិផល។ យ៉ាងសមហេតុផល វាត្រូវបានរំពឹងទុកថាព័ត៌មាននេះត្រូវបានរួមបញ្ចូលក្នុងចំនួនទំព័រ ៧៥០ ដែលបានបែងចែកឱ្យគាត់សម្រាប់សារណាបណ្តឹង

---

[6] ឯកសារ **F55/1** ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌ ៤-៥។

[7] *សូមមើល* ឯកសារ **F49** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់គាត់, ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ("សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រ"), កថាខណ្ឌ ៣៦ (ផ្នែកសម្រេចសេចក្តី)។

សាទុក្ខរបស់គាត់។ វាទំនងថា ការណ៍នេះមិនត្រូវបានធ្វើឡើងទេ ដើម្បីជៀសវាងមិនឲ្យលើសពីចំនួនទំព័រកំណត់របស់ អ.ជ.ត.ក។ ទោះជាយ៉ាងណា ជម្រើសរបស់ ខៀវ សំផន ក្នុងការផ្តល់ព័ត៌មានទាំងនេះនៅក្នុងឧបសម្ព័ន្ធ ដែលផ្ទុយទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ខ្លួននោះ មិនគួរទទួលបានការអនុញ្ញាតដើម្បីធ្វើឲ្យភាគីដែលប្រឆាំងទៅនឹងបណ្តឹងសាទុក្ខរបស់គាត់ចាញ់ប្រៀបនោះទេ។ ការបដិសេធសំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំចំនួនទំព័របន្ថែមក៏ធ្វើដូចនោះដែរ គឺធ្វើឲ្យពួកគេចាញ់ប្រៀបតាមរយៈការមិនអនុញ្ញាតឲ្យពួកគេនូវចំនួនទំព័រគ្រប់គ្រាន់ ដើម្បីបញ្ចេញសម្តែងដើម្បីបង្ហាញចម្លើយតបរបស់ពួកគាត់ទៅនឹងបញ្ហានានាដែលបានលើកឡើងនៅក្នុងឧបសម្ព័ន្ធនោះ។

5. ហេតុដូច្នេះ ដើម្បីធានាបាននូវការប្រព្រឹត្តដោយសមភាពចំពោះសហព្រះរាជអាជ្ញា នៅក្នុងបណ្តឹងសាទុក្ខនេះ សហព្រះរាជអាជ្ញាស្នើសុំ ៣៥ ទំព័របន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងឧបសម្ព័ន្ធ ក។ ការណ៍នេះនឹងសមាមាត្រទៅនឹងសារណាបណ្តឹងសាទុក្ខចំនួន ៧៥០ ទំព័រ[8]។

## ខ. ចាំបាច់ត្រូវមានការឆ្លើយតបជាក់លាក់នានាទៅនឹងការដាក់បញ្ចូលគ្នារបស់ ខៀវ សំផន នូវសារណាមុនៗ តាមរយៈឯកសារយោងនៅក្នុងសារណារបណ្តឹងសាទុក្ខរបស់គាត់

6. ខៀវ សំផន សន្មតមិនត្រូវថា សហព្រះរាជអាជ្ញាអាចឆ្លើយតបទៅនឹងការដាក់រួមបញ្ចូលគ្នារបស់គាត់នូវសារណាមុនៗតាមរយៈឯកសារយោងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់គាត់តាមវិធីដូចគ្នានេះដែរ[9]។ ការសន្មតនេះមិនត្រឹមត្រូវដោយមូលហេតុពីរ។ ទីមួយ ខៀវ សំផន ខកខានមិនបានទទួលស្គាល់ថា សារណាដែលបានធ្វើឡើង*នៅមុន* សាលក្រមអង្គជំនុំជម្រះសាលាដំបូង ទំនងជាត្រូវបានធ្វើឡើងក្នុងគោលបំណងដែលពេលនេះខុសពីបណ្តឹងសាទុក្ខបច្ចុប្បន្ន។ កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខមានបទដ្ឋានសម្រាប់ការពិនិត្យឡើងវិញ និងយុត្តិសាស្ត្រពិសេស[10] ដែលសហព្រះរាជអាជ្ញាត្រូវតែប្រុងប្រយ័ត្ន នៅពេលដែលឆ្លើយតបទៅនឹងសារណាដែលត្រូវបានដាក់រួមបញ្ចូលគ្នាតាមរយៈឯកសារយោង។

7. ទីពីរ ខៀវ សំផន ខកខានមិនបានទទួលស្គាល់ថា សហព្រះរាជអាជ្ញានឹងមិនចាំបាច់ឆ្លើយតបទៅនឹងសារណាទាំងអស់ពីមុនរបស់គាត់ដោយមូលហេតុមួយចំនួន ឬក្នុងកម្រិតដែលថាពេលនេះត្រូវបាន

[8] ឯកសារ **F49** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៦ (ផ្នែកសម្រេចសេចក្តី)។

[9] ឯកសារ **F55/1** ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៦។

[10] *ឧទា.* ឯកសារ **F49** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ១៦។

តម្រូវសម្រាប់កិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ។ ជាផលវិបាក វាមិនអាចត្រូវបានសន្មតថា សហព្រះរាជអាជ្ញាបានឆ្លើយតបរួចហើយទៅនឹងសារណាពីមុនៗ ដែល ខៀវ សំផន ពេលនេះស្វែងរកពឹងផ្អែកលើគោលបំណងនៃបណ្តឹងសាទុក្ខរបស់គាត់នោះទេ។

8. ការដាក់រួមបញ្ចូលគ្នារបស់ ខៀវ សំផន នៃចំនួនទំព័រអប្បបរមា ២៣៦ ទំព័រ នៃសារណាពីមុន[11] វាផ្តល់ភាពចាំបាច់ដែលថា សហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតផ្តល់ឲ្យនូវទំព័របន្ថែមចំនួន ១១០ ទំព័រ ដែលឆ្លុះបញ្ចាំងត្រឹមត្រូវពីសមមាត្រ ដែល អ.ជ.ត.ក បានផ្តល់ជូនសហព្រះរាជអាជ្ញាសម្រាប់ការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

## គ. មិនមានការពន្យារពេលមិនសមស្របនឹងកើតឡើងទេ ប្រសិនបើទំព័របន្ថែមត្រូវបានផ្តល់ឲ្យនោះ

9. ការតវ៉ារបស់ ខៀវ សំផន ដែលថា ការផ្តល់ឲ្យសហព្រះរាជអាជ្ញានូវចំនួនទំព័របន្ថែម នឹងបណ្តាលឲ្យមានការពន្យារពេលដំណើរការបណ្តឹងសាទុក្ខនោះ គឺមិនមានមូលដ្ឋានទេ[12]។ គាត់ខកខានមិនបានបង្ហាញថាតើចំនួនទំព័របន្ថែមនេះ នឹងរំលោភទៅលើសិទ្ធិរបស់គាត់ "ត្រូវបានជំនុំជម្រះដោយឥតពន្យារពេល*យូរហួសហេតុ*"[13] ដោយរបៀបណានោះទេ ឬថាតើវារារាំងកិច្ចដំណើរការនីតិវិធីមិនឲ្យ"ធ្វើការជំនុំជម្រះក្នុងរយៈពេលមួយ*សមស្រប*"[14] ឬយ៉ាងណា។ ជាធម្មតាមិនគួរមានកង្វល់ថាចំនួនទំព័របន្ថែមដែលបានស្នើសុំនេះនឹងពន្យារពេលកិច្ចដំណើរការនីតិវិធីដោយមិនសមស្របនោះទេ។ អង្គជំនុំជម្រះនេះបានកត់សម្គាល់រួចមកហើយថា "ការិយាល័យរដ្ឋបាលនៅតែរក្សាផ្តល់សេវាបុគ្គលិកផ្នែកភាសាបន្ថែមដើម្បីជួយគាំទ្រការិយាល័យតុលាការ *ក្នុងការធានាបាននូវការបកប្រែទាន់ពេល* [...]"[15]។

---

[11] *សូមមើល* ឯកសារ **F55** សំណើរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩។

[12] ឯកសារ **F55/1** ចម្លើយតបរបស់ ខៀវ សំផន កថាខណ្ឌ ៦។

[13] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, ៩៩៩ UNTS ១៧១ មាត្រា ១៤(៣)(គ) (សង្កត់ន័យបន្ថែម) ដែលត្រូវបានទទួលស្គាល់នៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ មាត្រា ១២(២), ១៣(១) និងច្បាប់ស្តីពីការបង្កើតអោយមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ *ដូចដែលបានធ្វើវិសោធនកម្ម* កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ មាត្រា ៣៣ថ្មី, ៣៥ថ្មី។

[14] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិ.លើកទី៩) ដូចដែលបានពិនិត្យសាឡើងវិញកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ វិធាន ២១(៤) នៃវិធានផ្ទៃក្នុង (សង្កត់ន័យបន្ថែម)។

[15] ឯកសារ **F49** សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ កថាខណ្ឌ ៣៤ (សង្កត់ន័យបន្ថែម)។ *សូមមើលផងដែរ* អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "ផែនការបិទ

10. ប្រសិនបើ អ.ជ.ត.ក ពិចារណាបដិសេធសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីជៀសវាងការពន្យារពេលនោះ សហព្រះរាជអាជ្ញាផ្តល់ជាយោបល់ដោយគោរពថា ការបដិសេធចំនួនទំព័របន្ថែម និងជាជំនួសវិញ អនុញ្ញាតឱ្យសហព្រះរាជអាជ្ញាមានឱកាសឆ្លើយតបទៅនឹងឧបសម្ព័ន្ធ ក និងសារណាដែលដាក់រួមបញ្ចូលគ្នាដោយឯកសារយោងរបស់ ខៀវ សំផន នៅពេលសវនាការបណ្តឹងសាទុក្ខ[16] គឺមិនមែនជាការចាត់ចែងរឿងក្តីដ៏មានប្រសិទ្ធិភាពឡើយសម្រាប់មូលហេតុដូចខាងក្រោម។ ទីមួយ វានឹងមិនអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើចម្លើយតបរបស់ពួកគាត់ឱ្យបានពេញលេញទៅនឹងបញ្ហាដែលបានចោទប្រកាន់នៅក្នុងសារណាឆ្លើយតបរបស់ពួកគេនោះឡើយ ដូច្នេះធ្វើឱ្យ អ.ជ.ត.ក មិនមានឱកាសវាយតម្លៃឱ្យបានពេញលេញលើចម្លើយតបនោះ មុនពេលអំណះអំណាងផ្ទាល់មាត់។ ទីពីរ វានឹងនាំឱ្យអង្គជំនុំជម្រះមិនទទួលបានអត្ថប្រយោជន៍ពីការយល់ដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីអំពីចម្លើយតបពេញលេញរបស់សហព្រះរាជអាជ្ញានៅមុនពេលដាក់សារណាតបរបស់ខ្លួន។ ដូចដែលអង្គជំនុំជម្រះនេះ បានសម្រេចរួចមកហើយ "គោលបំណងតែមួយគត់" នៃការអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការពិនិត្យមើលសារណាតបរបស់សហព្រះរាជអាជ្ញា មុនពេលដែលពួកគេដាក់សារណាតបរបស់ខ្លួន គឺដើម្បីការពារមិនឱ្យមានបញ្ហាត្រួតគ្នា និងជាន់គ្នា[17]។ ការបង្ខំឱ្យសហព្រះរាជអាជ្ញាលើកឡើងអំពីសម្ភារៈនៅក្នុងឧសម្ព័ន្ធ ក និងឯកសារយោងដែលត្រូវបានដាក់រួមបញ្ចូលគ្នាដោយ ខៀវ សំផន នៅក្នុងអំណះអំណាងផ្ទាល់មាត់ នឹងធ្វើឱ្យប៉ះពាល់ដល់គោលបំណងនេះ។

11. ហេតុដូច្នេះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណើរបស់របស់ពួកគាត់ស្នើសុំចំនួនទំព័របន្ថែម គួរតែទទួលបានការអនុញ្ញាត ដើម្បីធានាលទ្ធភាពរបស់ពួកគេក្នុងការដាក់ចម្លើយតបមួយគ្រប់ជ្រុងជ្រោយទៅនឹងបញ្ហាទាំងអស់ដែលបានលើកឡើងដោយ ខៀវ សំផន តាមវិធីដ៏មានប្រសិទ្ធផល។ លើសពីនេះទៀត សំណើរបស់ពួកគាត់គួរត្រូវបានអនុញ្ញាត ដើម្បីធានាឱ្យបាននូវការប្រព្រឹត្តិប្រកបដោយសមភាព។

---

បញ្ចប់ អ.វ.ត.ក" ពិនិត្យសាឡើងវិញនៅថ្ងៃទី២៣, ៣១ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១៧ ត្រង់ https://www.eccc.gov.kh/sites/default/files/Completion%20Plan%20Rev.%2023.pdf។

[16] *សូមមើល* ឯកសារ **F23/1** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ និងពេលវេលាក្នុងការឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីប្រឆាំងនឹងសាលក្រមនៃសំណុំរឿង០០២/០១ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ កថាខណ្ឌ ១០។

[17] ឯកសារ **F52/1** សេចក្តីសម្រេចលើសំណើពាក់ព័ន្ធនឹងសារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ២៥។ *សូមមើលផងដែរ* កថាខណ្ឌ ២២។

## V. ដំណោះស្រាយដែលបានស្នើឡើង

12. តាមសម្អាងហេតុដូចបានគូសបញ្ជាក់ខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យ អ.ជ.ត.ក៖

ក. បដិសេធ ឧបសម្ព័ន្ធ ក ប្រសិនបើខ្លួនរកឃើញថា ឧបសម្ព័ន្ធនេះមិនរួមចំណែកជាសារវ័ន្ត ដល់បណ្តឹងសាទុក្ខរបស់ ខៀវ សំផន ទេនោះ ឬជាជម្រើសម្យ៉ាងទៀត អនុញ្ញាតផ្តល់ ៣៥ ទំព័របន្ថែម ដើម្បីឆ្លើយតបទៅនឹងឧបសម្ព័ន្ធនេះ លើសពីចំនួនកំណត់ ៣៥០ទំព័រ បច្ចុប្បន្ន សម្រាប់ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខ ដែលបានពង្រីករបស់ ខៀវ សំផន និង

ខ. អនុញ្ញាតផ្តល់ ១១០ទំព័របន្ថែម ដើម្បីឆ្លើយតបទៅនឹងបញ្ហានានាដែលបានដាក់បញ្ចូលគ្នា ដោយឯកសារយោង លើសពីចំនួនកំណត់ ៣៥០ទំព័រ បច្ចុប្បន្ន សម្រាប់ចម្លើយតបទៅនឹង បណ្តឹងសាទុក្ខដែលបានពង្រីករបស់ ខៀវ សំផន។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញាជាតិ | ភ្នំពេញ | [signature] |
| | **លោកស្រី Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | | [signature] |